កាលបរិច្ឆេទ: ថ្ងៃទី ០៨ ខែមីនា ឆ្នាំ២០១៨

# មេរៀនដំណាំត្រកួនស

## I. ប្រវត្តិសង្ខេបនៃការដាំត្រកួនស

ដំណាំត្រកួនជាដំណាំងាយស្រួលដាំជាងគេបំផុត ក្នុងចំណោមដំណាំផ្សេងៗទៀត ហើយវាជាប្រភេទដំណាំឆ្លងកាត់។

អាយុកាលរបស់ដំណាំត្រកួនចាប់តាំងពីពេលដាំ ឬសាបព្រោះរួចមកបានអាយុប្រហែលត្រឹមតែ២២ទៅ២៥ថ្ងៃប៉ុណ្ណោះអាចប្រមូលផលបាន អាចយកទៅធ្វើជាបន្លែសម្រាប់ហូបឬសម្រាប់លក់ដូរ អាចទទួលបានប្រាក់កំរៃយ៉ាងងាយ។ ពូជដំណាំនេះ មិនរើសរដូវកាលដាំដុះឡើយ ។

ដំណាំត្រកួនត្រូវការកំដៅសម្រាប់ទ្រទ្រង់សរីរាង្គរបស់វាចាប់ពី៨០ទៅ១០០ភាគរយ។ បន្ថែមពីនោះ វាត្រូវការទឹកនិងសំណើមត្រជាក់ជាប់ជាអចិន្ត្រៃយ៍ ទើបធ្វើឱ្យវាល្អនិងឆាប់ទទួលបានផល។

## II. គម្រោងដាំត្រកួនស

យើងត្រូវរៀបចំគម្រោងសម្រាប់ដាំត្រកួនសដូចតទៅ៖

១- ជ្រើសរើសទីតាំងដីសម្រាប់ដាំដុះ ហើយកាប់គាស់ភ្ជួររាស់ហាលដីឲ្យបានល្អជាមុនប្រហែល១សប្តាហ៍

២- មានប្រភពទឹកសម្រាប់ប្រើប្រាស់

៣- មានពូជ

៤- មានជីធម្មជាតិសម្រាប់ប្រើប្រាស់

៥- មានឧបករណ៍ពាក់ព័ន្ធដូចជា ចប ឡាំង បង្គី កម្លាំងអូសទាញ។ល។

៦-ចំណុចសំខាន់មួយទៀតគឺ កម្លាំងពលកម្មសម្រាប់ថែទាំនិងមានបច្ចេកទេស។

## III. វិធីសាស្ត្រ ឬបច្ចេកទេសនៃការដាំត្រកួនស

យើងមានបច្ចេកទេសសម្រាប់ដាំត្រកួនសដូចខាងក្រោមៈ

១- សង់រងសម្រាប់ដាំជាមុន បន្ទាប់ពីការកាប់គាស់ភ្ជួររាស់រួចមក

២- លាយឬច្របល់ជីធម្មជាតិដាក់ក្នុងរង

៣- ឆូតចង្អូរកាត់ទទឹងរងសម្រាប់ដាំ

៤-យកគ្រាប់ពូជមកខ្ចប់ជាមួយនឹងក្រណាត់ ហើយដាក់ត្រាំនៅក្នុងទឹកធុងរយៈពេល១យប់។

៥- បន្ទាប់ពីត្រាំគ្រាប់ពូជ១យប់រួចមក យកគ្រាប់ពូជនោះមកដាំ

៦-ស្រោចទឹកនៅក្នុងពេលព្រឹកនិងពេលល្ងាចព្រមទាំងថែទាំវាជាប្រចាំ។

កាលបរិច្ឆេទៈ ថ្ងៃទី ០៨ ខែមីនា ឆ្នាំ២០១៨

បញ្ជាក់ពីចំណុចសំខាន់នៃការសង់រងៈ ក្បាលរងទំហំទទឹងស្មើ១ម៉ែត្រ បណ្តោយរងយកទំហំស្មើ៥ឬ១០ម៉ែត្រ កំពស់រឹមរងស្មើ១០សង់ទីម៉ែត្រ ទ្រូងរងនីមួយៗត្រូវចោលគម្លាតពីគ្នាស្មើ៤០សង់ទីម៉ែត្រ(៤តឹករង្វាស់ខ្មែរ) (ពីរងមួយទៅរងមួយ)៕

**សូមអរគុណ**

---

រៀបចំដោយលោក ភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្រ្តីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

កាលបរិច្ឆេទៈ ថ្ងៃទី ០៨ ខែមីនា ឆ្នាំ២០១៨

# មេរៀនដាំឈាំសាឡាត់

## បច្ចេកទេសនៃការដាំសាឡាត់

### ក-ការរៀបចំដី

១) ភ្ជួរដីហាលចោលរយៈពេលពី៧ទៅ១៥ថ្ងៃ

២) ត្រូវភ្ជួររាស់ដីចំនួន២ឬ៣ដងដើម្បីឲ្យពពួកសត្វល្អិតចង្រៃស្លាប់ឲ្យស្មៅរលួយ ឲ្យដីមានជីជាតិ មានខ្យល់អុកស៊ីសែន និងធ្វើឲ្យដីធូនិងម៉ត់ល្អ។

៣) ភ្ជួរជម្រៅទៅក្នុងដីឲ្យបាន៣តឹកដើម្បីឲ្យដីមានសំណើមបានជ្រៅ និងធ្វើឱ្យដីធូ។

### ខ-ការរៀបចំថ្នាលនិងរង

១) ថ្នាលត្រូវធ្វើទទឹង១ម៉ែត្រឬ១,២ម៉ែត្រ បណ្ដោយថ្នាលយកតាមតម្រូវការ ចំណែកឯកំពស់ថ្នាលយកប្រវែងពី១០ទៅ២០សង់ទីម៉ែត្រ ឬ២៥សង់ទីម៉ែត្រក៏បាន។

២) សំរាប់រងក៏ធ្វើដូចថ្នាលដែរតែបណ្ដោយអាចវែង

៣) រងឬថ្នាលបណ្ដោយ២០ម៉ែត្រ ត្រូវប្រើជីកំប៉ុស្តឬជីធម្មជាតិផ្សេងៗចំនួន២០ទៅ២៥បង្គី។

រៀបចំដោយលោក ភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)

៤) ចន្លោះពីរងមួយទៅរងមួយឬចន្លោះផ្លូវដើរយកប្រវែងពី៣ទៅ៤តឹក

**គ-ការដាំដុះ**

១) ក្រោយពីធ្វើថ្នាលរួចហើយត្រូវយកជីធម្មជាតិឬកំប៉ុស្តទៅរោយពីលើរួចច្របល់នឹងដីថ្នាលឲ្យបានចូលគ្នាល្អផង។

២) យកគ្រាប់ពូជខ្ចប់នឹងក្រណាត់រួចត្រាំទឹក១យប់ផ្អាប់១យប់ *(ពូជដែលនៅសល់ពីសាបត្រូវដាក់ក្នុងដបឬកំប៉ុងរួចបិទគំរបឲ្យជិតកុំឲ្យខ្យល់ចេញចូលរួច)*

៣) យកពូជដែលផ្អាប់រួចនោះទៅរោយឬសាបពីលើថ្នាលដែលបានរៀបចំទុកកាលពីពេលមុន។

៤) ត្រូវយកកំទេចចំបើងឬអំពុកចំបើងទៅរោយពីលើបន្ទាប់ពីសាបគ្រាប់រួច ដើម្បីការពារដំណក់ទឹកនិងរក្សាសំណើមបានយូ។

៥) ត្រូវធ្វើដំបូលការពារកំដៅថ្ងៃនិងទឹកភ្លៀងផង

៦) ក្រោយពីកូនសាឡាត់ដុះបានរយៈពេលពី១០ទៅ១៥ថ្ងៃគេអាចដកវាយកទៅស្ទូងបានត្រូវជ្រើសកូនណាដែលល្អ**ត្រូវចាំ** *មុនពេលដកកូនទៅស្ទូងត្រូវផ្អាកស្រោចទឹកនិងជីប៉ូវរយៈពេល២ថ្ងៃសិនទុកអោយដើមរឹងមាំ។*

៧) ត្រូវចាំពេលដាក់ជីកំប៉ុស្តនៅលើរងនោះត្រូវទុករយៈពេលពី២ទៅ៣ម៉ោងសិនដើម្បីឲ្យជីអស់កំស្លួលកំដៅសិនចាំដាំវាបើដាំឬស្ទូងភ្លាមៗវាអាចភាយកំដៅនឹងធ្វើឲ្យកូនដំណាំរលួយបាន ព្រោះវានៅមានសារធាតុអាម៉ូញាក់។

រៀបចំដោយលោក ភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្រ្តីគម្រោងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)

៨) ការដាំត្រូវដាំគំលាតគ្នាពីគុម្ពមួយទៅគុម្ពមួយប្រវែង១៥សង់ទីម៉ែត្រ និងត្រូវធ្វើដំបូលការពារកូនសន្ទូងរយៈពេល២ឬ៣ថ្ងៃចាំបើកវា។

## ឃ-ការថែទាំ

១) ស្រោចទឹកក្នុង១ថ្ងៃឲ្យបាន២ដងយ៉ាងតិចគឺព្រឹកនិងល្ងាច។

២) ក្រោយពីសាទ្បាត់ស្ទូងបានរយៈពេល៧ឬ៨ថ្ងៃ ត្រូវបោចស្មៅនិងជ្រោយដីជ្រុំជើង កុំទុកឲ្យស្មៅវែងពេក។

៣) ត្រូវប្រើប្រាស់ជីបំប៉នធម្មជាតិពេលសាឡាត់អាយុបាន៨ថ្ងៃ ត្រូវស្រោច៣ថ្ងៃស្រោចម្តងនិងពេលសាឡាត់អាយុ១២ថ្ងៃត្រូវស្រោច១អាទិត្យម្តង។

## ង-វិធីការពារ

១) ត្រូវដាំរុក្ខជាតិនៅក្បែរដើម្បីបន្លាចសត្វចង្រៃដូចជា ស្លឹកគ្រៃ ផ្កាស្បៃរឿងឬប្រើថ្នាំសំលាប់សត្វល្អិតដែលធ្វើពីធម្មជាតិ ទឹក១៧លីត្រនិងទឹកថ្នាំធម្មជាតិ ១លីត្រសំរាប់បាញ់។

- ***ថ្នាំធម្មជាតិ*** ដូចជា បណ្តូលពេជ្រ គ្រាប់ស្លែង មើមក្តួច ផ្លែស្លាក់ ប្រង់រំដេង ស្លឹកទាបបាយ។ល។ យកមកចិញ្រ្ចាំឲ្យម៉ដ្ត រួចត្រាំទឹកផ្អាប់ទុករយៈពេល១ខែ តែត្រូវឧស្សាហ៍កូរវាឲ្យបានញឹកញាប់ បន្ទាប់មកអាចចម្រស់វាដាក់ទុកក្នុងដបឬប៊ីដុងហើយទុកក្នុងកន្លែងត្រជាក់ល្អ។

➢ ***ជីប៉ូវធម្មជាតិ*** ចេកទុំ៣kg ស្ពៃក្ដោប១kg ត្រសក់ស្រូវទុំ៣kg ល្ហុងទុំ៣kg យកវាមកចិញ្ច្រាំឲ្យម៉ដ្ឋ រួចច្របល់ចូលគ្នារួចផ្អាប់ទុករយៈពេល១ខែ អាចចម្រស់វាមកប្រើបាន។

➢ ***របៀបប្រើ*** កូនដំណាំតូច *ជី២ស្លាព្រាបាយនិងទឹក២០លីត្រ* សំរាប់ដំណាំពីតូចដល់អាយុ២០ថ្ងៃ ត្រូវស្រោចក្នុង១ថ្ងៃ២ដង ត្រូវស្រោចពេលល្ងាច បើស្រោចពេលព្រឹកឬថ្ងៃ បន្ទាប់ពីស្រោចបានរយៈពេល១០នាទី ត្រូវស្រោចទឹកធម្មតាលាងស្លឹកវាវិញ។ ជីប៉ូវនេះវាអាចទាក់ទាញសត្វមានប្រយោជន៍ដូចជាឃ្មុំ ឱម៉ាល់ និងស្រាំងជាដើម។

## ច-ការប្រមូលផល

១) ពេលសាឡាត់មានអាយុបាន៣០-៣៥ថ្ងៃ គេចាប់ផ្ដើម ប្រមូលផលបានហើយ (ពីសាបដល់ប្រមូលមាន៣៥ថ្ងៃ)។

២) មុនពេលដកប្រមូលផលត្រូវផ្អាកស្រោចទឹក១ថ្ងៃ

៣) ការដកត្រូវដកពេលព្រឹកឬល្ងាចតែពេលល្ងាចវាប្រសើរជាងពេលព្រឹក។

៤) របៀបប្រមូលត្រូវប្រើកូនចបជីកឬកាំបិតច្រិបចាក់ឫសរួចចាប់ដកវារួចរលាស់ដីផង។

៥) ត្រូវដាក់វាក្នុងម្លប់រួចលាងទឹកគល់វាឲ្យបានស្អាត បន្ទាប់មកដាក់វាទៅក្នុងជាលដោយមានទ្រាប់ស្លឹកចេកដោយទុកចន្លោះឲ្យមានខ្យល់ចេញចូលផង៕

**សូមអរគុណ**